រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ០៣៤ សរណន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១១

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ជម្រាបមក

## ឯកឧត្តមអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** : សេចក្តីណែនាំបន្ថែមស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

**យោង** :
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ០១១ សណន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ១១៥៣ ស.ជ.ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការចេញប័ណ្ណទទួលស្គាល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមឯកឧត្តមអភិបាលរាជធានី ខេត្តជ្រាបថាកន្លងមក ក្រសួងបានចេញលិខិតចំនួនពីរ គឺលិខិតលេខ ១០២៧ ស.ជ.ណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ និងលិខិតលេខ ១៦៨ ស.ជ.ណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ដើម្បីជំរុញការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានកំណត់ថា "ការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ"។ ផ្អែកតាមការអនុវត្តជាក់ស្តែង ក្រសួងនៅតែសម្គាល់ឃើញថា ការរៀបចំបែបបទស្នើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែមានការយឺតយ៉ាវ មិនបានឆ្លើយតបតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៅឡើយ។

ដូច្នេះ ដើម្បីកាត់បន្ថយពេលវេលា និងធានាឱ្យការរៀបចំបែបបទស្នើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បានត្រឹមត្រូវ ស្របតាមគោលការណ៍ដូចមានចែងក្នុងមាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំជាថ្មីម្តងទៀតដូចខាងក្រោម :

១- អភិបាលរាជធានី ខេត្ត ត្រូវពិនិត្យមើលអំពីស្ថានភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នានាក្នុងរាជធានី ខេត្តរបស់ខ្លួនជាប្រចាំ។ ករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបាត់បង់សមាជិកភាព

អភិបាលរាជធានី ខេត្ត ដោយមានទីចាត់ការគ្រប់គ្រងធនធានមនុស្សជាជំនួយការ ត្រូវជំរុញឱ្យក្រុមប្រឹក្សា ឃុំ សង្កាត់នោះ លើកសំណើសុំផ្លាស់ប្តូរជាបន្ទាន់។ សំណើសុំផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់នេះ ត្រូវបញ្ជូនត្រង់មកអភិបាលរាជធានី ខេត្តក្នុងរយៈពេលយ៉ាងយូរពីរ (០២) ថ្ងៃ ដោយពុំចាំបាច់មានមូលវិចារពីសាលាក្រុង ស្រុក ខណ្ឌឡើយ។

២- សាលាក្រុង ស្រុក ខណ្ឌ ត្រូវជួយសម្របសម្រួល និងបញ្ជូនសំណើសុំផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់នេះ មកសាលារាជធានី ខេត្ត ក្នុងករណីមានការស្នើសុំឱ្យជួយពីក្រុមប្រឹក្សាឃុំ សង្កាត់។

៣- រយៈពេលមួយ(០១)ថ្ងៃ ក្រោយពីបានទទួលសំណើសុំផ្លាស់ប្តូរពីក្រុមប្រឹក្សាឃុំ សង្កាត់ខាងលើ ទីចាត់ការគ្រប់គ្រងធនធានមនុស្សត្រូវជួយអភិបាលរាជធានី ខេត្ត ធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញឱ្យបានច្បាស់លាស់ ហ្មត់ចត់ និងធានាភាពត្រឹមត្រូវទៅតាមនីតិវិធី ហើយមិនត្រូវឱ្យមានការរំលងលេខរៀងក្នុងបញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងបញ្ជីបេក្ខជននីមួយៗជាដាច់ខាត។

៤- ប្រសិនបើសំណុំឯកសារនៃសំណើសុំផ្លាស់ប្តូរនេះត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ អភិបាលរាជធានី ខេត្ត ត្រូវចំណារលើសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សឃុំ សង្កាត់នោះ រួចបញ្ជូនមកក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងយូរ០៧ថ្ងៃ បន្ទាប់ពីថ្ងៃមានករណីបាត់បង់សមាជិកភាព និងត្រូវចម្លងមួយច្បាប់ផ្ញើមកនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (ទូរសារលេខ ០២៣ ៧២០ ០៥១ ឬ អ៊ីមែល : malyna@ncdd.gov.kh ឬ vicha@ncdd.gov.kh ឬ solidaskh@yahoo.com)។

៥- នៅពេលទទួលបានសំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សឃុំ សង្កាត់ខាងលើ និងក្រោយពីបានពិនិត្យឃើញថា សំណុំឯកសារនេះមានភាពត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានត្រូវរៀបចំប្រកាសទទួលស្គាល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ សម្រេចក្នុងរយៈពេលយ៉ាងយូរបី(០៣)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសំណើ។

៦- បន្ទាប់ពីអភិបាលរាជធានី ខេត្តបានទទួលប្រកាសស្តីពីការប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានផ្ញើជូនភ្លាម អភិបាលរាជធានី ខេត្តត្រូវចាត់ចែងការប្រកាសចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបន្ទាន់។ ករណីនេះ អតីតមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានផ្លាស់ចេញ ត្រូវអស់សុពលភាពក្នុងការបំពេញមុខងារ និង/ឬចុះហត្ថលេខាលើរាល់លិខិតស្នាមនានា ចាប់ពីថ្ងៃចេញប្រកាសស្តីពីការប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ភ្លាម។

៧- អភិបាលរាជធានី ខេត្តត្រូវរៀបចំឱ្យមានមន្ត្រីបង្គោលនៅក្នុងទីចាត់ការគ្រប់គ្រងធនធានមនុស្សឱ្យទទួលខុសត្រូវលើការងារផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន។ អភិបាលរាជធានី ខេត្តត្រូវបញ្ជូនឈ្មោះមន្ត្រីបង្គោលនោះ ដោយភ្ជាប់ជាមួយ លេខទូរស័ព្ទ

ទូរសារ និង អ៊ីមែល (បើមាន) មកក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) ក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃក្រោយកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងនេះ។

៨- សេចក្តីណែនាំនេះ សម្រាប់អនុវត្តបំពេញបន្ថែមលើសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ០១១ ស.ណ.ន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែខ្លឹមសារដូចមានចែងក្នុងចំណុច២នៃសេចក្តីណែនាំ លេខ ០១១ ស.ណ.ន។

៩- ដើម្បីធានាឱ្យការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលតម្រូវឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប័ណ្ណសម្គាល់ខ្លួន អភិបាលរាជធានី ខេត្តត្រូវជំរុញការចេញប័ណ្ណសម្គាល់ខ្លួនជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលពុំទាន់មាន ជាបន្ទាន់ ដោយអនុវត្តសេចក្តីណែនាំលេខ ១១៥៣ ស.ជ.ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការចេញប័ណ្ណទទួលស្គាល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តមអភិបាលរាជធានី ខេត្ត ចាត់ចែងអនុវត្តគោលការណ៍ណែនាំខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អភិបាលក្រុង ស្រុក ខណ្ឌ
  "ដើម្បីជូនជ្រាប"
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ